# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ ដូងថ្មី

## រយៈពេល ៣ ឆ្នាំ

## (២០០៨-២០១០)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨~ ២០១០)

ឈ្មោះសហគមន៍នេសាទ : **ដូងជ្រុំ**

ភូមិ : ដូងជ្រុំ និងទូលធ្លា

ឃុំ : បឹងបត់កណ្ដាល

ស្រុក : បាកាន

ខេត្ត : ពោធិ៍សាត់

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **ដូងជ្រុំ** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតលើកទី ១ នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០០៤ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦។

សហគមន៍នេសាទ **ដូងជ្រុំ** មានទីតាំងស្ថិតនៅក្នុងភូមិ **ដូងជ្រុំ** ឃុំបឹងបត់កណ្ដាល ស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលមានសមាជិកសរុបចំនួន ៦៧៧នាក់ និង មានគណៈកម្មការចំនួន ១១ នាក់ ស្រីចំនួន ០៣ នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ៣៣៧ គ្រួសារ។

កន្លងមក សហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ *មហាសន្និបាត បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ អនុម័តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងសេចក្តីថ្លែងការណ៍ ផែនទីកន្លែងនេសាទសហគមន៍ អប់រំច្បាប់ផ្សព្វផ្សាយ សហការបង្ក្រាបបទល្មើស ល្បាតជាប្រចាំ រៀបចំផែនការសកម្មភាព ។*

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក-ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន ១៧១១នាក់ ប្រុស ១២៧៩នាក់ ស្រី ៤៣២នាក់។ ក្នុងនោះមានជនជាតិខ្មែរចំនួន ១៥០១ នាក់ ខ្មែរឥស្លាមចំនួន ២១០ នាក់ អណិកជនវៀតណាមចំនួន ០ នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៦៧ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៣០ នាក់ ស្រី ១៦ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ២៦ នាក់ ស្រី ២០ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៩ នាក់ ស្រី ៨ នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទ មាន ២៤ នាក់ ស្រី ១៧ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ៨៨%។ ក្រៅពីនេះមានអ្នកកាន់សាសនាអ៊ីស្លាម ប្រមាណ ១២% សាសនាកាតូលិកប្រមាណ ០%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ៤០៨ នាក់ ស្រី ១០៨ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ១២៩ នាក់ ស្រី ១០២ នាក់ កំរិតមធ្យមសិក្សាចំនួន ១១៨នាក់ ស្រី ៤៦ នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន ២ នាក់ ស្រី ០ នាក់។

**ខ -មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

| | | | |
|---|---|---|---|
| - ធ្វើនេសាទចំនួន | ៣៤០ | គ្រួសារ | |
| - ជំនួញត្រីចំនួន | ៥ | គ្រួសារ | |
| - ធ្វើស្រែចំនួន | ៣៤០ | គ្រួសារ | ទំហំ ៨៩៧ ហិកតា |
| - ធ្វើវារីវប្បកម្មចំនួន | ៣ | គ្រួសារ | ទំហំ ១៨០ ម$^{២}$ |
| - ដាំបន្លែចំនួន | ៣៤០ | គ្រួសារ | ទំហំ ៥,២៨ ហិកតា |
| - ជាងផ្ទះចំនួន | ១០០ | គ្រួសារ | |
| - ធ្វើសិប្បកម្មចំនួន | ២៩ | គ្រួសារ | ( ម៉ាស៊ីនកិនស្រូវ បិតស្រា សាកអាគុយ គោយន្ត) |
| - លក់ដូរ ចំនួន | ២០ | គ្រួសារ | |
| - ចិញ្ចឹមសត្វ | ៣៤០ | គ្រួសារ | |
| - លក់ពលកម្ម | ៣១៩ | គ្រួសារ | |
| - ស៊ីស្នូលច្រូត | ២៥០ | គ្រួសារ | |
| - បេះសណ្តែក | ១៥០ | គ្រួសារ | |
| - ជាងកាត់សក់ | ១០ | នាក់ | |
| - រត់ម៉ូតូឌុប | ១០ | នាក់ | |
| - ឡើងត្នោត | ១០ | នាក់ | |
| - ពេទ្យសត្វ | ២ | នាក់ | |
| - គ្រូបង្រៀន | ៤ | នាក់ | |
| - មេដោះ | ៤ | នាក់ | |
| - ចុងភៅ | ៥ | នាក់ | |

**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍ **ដូងជ្រុំ** ជាកន្លែងដែននេសាទដែលត្រូវបានរដ្ឋប្រគល់អោយសហគមន៍ដើម្បីចូលរួមគ្រប់គ្រង ថែរក្សាការពារ អភិរក្ស និងអភិវឌ្ឍន៍ ធនធានជលផលប្រកបដោយចិរភាព។

កន្លែងនេសាទសហគមន៍ **ដូងជ្រុំ** មានទំហំ ២៦១៦ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង សហគមន៍នេសាទជីរនាត
- ខាងត្បូងទល់នឹង ឃុំត្រពាំងជង

- ខាងកើតទល់នឹង ស.នរបងរមាស
- ខាងលិចទល់នឹង ស.ន ចិនតាយ

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍ **ដូងជ្រុំ** មានបឹងចំនួន ៣៥ អូរចំនួន១ ព្រែកចំនួន១ ត្រពាំងចំនួន២៥ បៀចំនួន១៦។ **(ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី ១)** ។

- បឹងឈ្មោះ .................... ទំហំ .................. នេសាទពីខែ ......... ដល់ខែ .................. ។
- អូរឈ្មោះ ................. ទំហំ ................... នេសាទពីខែ............ដល់ខែ .................. ។
- ត្រពាំងឈ្មោះ.......... ទំហំ ..................... នេសាទពីខែ ដល់ខែ ។
- បៀចំនួន...................ឈ្មោះ........................នេសាទពីខែ .............ដល់ខែ............. ។
- ព្រៃលិចទឹកមានទំហំសរុប ទំហំ ១២៣៣,៧៦ ហិកតា
- ព្រៃឈ្មោះ ............................ ទំហំ ...................ហិកតា
- ព្រៃឈ្មោះ .............................. ទំហំ ...................ហិកតា
- ដីទំនាបលិចទឹកមានទំហំសរុប ៧៤,០៩ ហិកតា

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹងឈ្មោះ **បឹងហា** ទំហំ ២៥,៦៨ ហិកតា *( បណ្តោយ ៦០០ ម ទទឹង ៧០ ម)*
- បឹងឈ្មោះ **បឹងជាតិអង្គុល់** ទំហំ ១០,៣៧ ហិកតា *( បណ្តោយ ២០០ ម ទទឹង ២០០ ម)*
- បឹងឈ្មោះ **បឹងកំពង់រលីង** ទំហំ ៨,៧៤ ហិកតា *( បណ្តោយ ៣០០ ម ទទឹង ២០០ ម)*

**ឃ. ធនធានជលផល**

- ប្រភេទត្រី ( ត្រីរស់ ឆ្តោ រៀល ត្រីឆ្លាំង ត្រីក្រាយ តានេល សណ្តាយ ផ្ទោង ដំរី ...)
- ប្រភេទវារីសត្វ ( អណ្តើក ពស់ ក្តាម ខ្ចៅ ខ្យង លៀស គ្រំ )
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ( រាំង គ្រស់ ត្នួ..........ព្រលិត ត្រកួន..............)

**(ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី ២)** ។

## ៤. ការធ្វើនេសាទ

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៣៦៩ នាក់ ស្រី ១០២នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៧០ នាក់ ស្រី ២៥ នាក់
- ប៉ាន់ស្មាន អ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៤៨៣នាក់ ស្រី ១៥០នាក់

**ខ. ឧបករណ៍នេសាទ**

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍៖

| ល.រ | ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ទំហំ, ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ...ដល់ ខែ....) |
|---|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ២៥ | ៣០០០ម | ខែ៨ ដល់ ខែ១១ |
| ២ | សំណាញ់ | វង់ | ៣២ | ០,០៣-០,០៤ម x ៥-៦ម | ខែ១ ដល់ ខែ៥ |
| ៣ | ទ្រូ | គ្រឿង | ៣៧ | ០,២ម x ១ម | ខែ៩ ដល់ ខែ១ |
| ៤ | ឈ្នាង | គ្រឿង | ៣៤ | ០,៥ម | ខែ៥ ដល់ ខែ១ |
| ៥ | ជូអន្ទង់ | គ្រឿង | ៤០០ | | ខែ៤ ដល់ ខែ៦ |
| ៦ | សន្ទូចរនង | ផ្លែ | ២៧ | ផ្លែ១២-១១ ប្រវែង២០០០ម | ខែ៨ ដល់ ខែ១១ |
| ៧ | អួនហ៊ុំ | គ្រឿង | ២ | ១០០ម x ០,០៤ម | ខែ១ ដល់ ខែ៤ |
| ៨ | អួនអូស | គ្រឿង | ១៨៧ | ០,០៣-០,០៤ម x ៣៥ម | ខែ១ ដល់ ខែ៥ |
| ៩ | ឆក់ | គ្រឿង | ១១១ | | ខែ១ ដល់ ខែ១២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| កាណូត | ០ | ០ | ០ |
| ទូកតូច | ២០ | ២០០-៣០០គ.ក | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ៖

| ល.រ | ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ១៥ | ០,០៣៥ម-០,០៥៥ x ២៥០ម |
| ២ | សំណាញ់ | វង់ | ១០ | ០,០២៥-០,០៥៥ម x ៥-៦ម |
| ៣ | អួនអូស | គ្រឿង | ២៥ | ០,០៣-០,០៤ម x ៣៥ម |
| ៦ | សន្ទូចរនង | ផ្លែ | ២០០-១១០០ | ផ្លែ១២-១១ ប្រវែង១១០០ម |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូក | ៥ | ២០០-៣០០ គ.ក្រ | |
| កាណូត | ០ | ០ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ៖

| ល.រ | ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង |
|---|---|---|---|---|
| ១ | មងរាយ | ម៉ែត្រ | ៥០ | ០,០៥៣ម x ០,០៥៥ម x ៥០០ម-៧០០ម |
| ២ | មងអូស | គ្រឿង | ៥២ | ០,០៣៥-០,០៤៥ម x ៣០-៤៥ម |

| | | | | |
|---|---|---|---|---|
| ៣ | លាន់ | គ្រឿង | ៦៨ | ២.៥ម x 0.៨ម |
| ៤ | ជួអន្ទង់ | គ្រឿង | ៦១ | |
| ៥ | សន្ទូចរនង | ផ្លែ | ១២0 | ផ្លែ១២-១១ ប្រវែង៧000ម |
| ៦ | ដាយ ច្បូ | គ្រឿង | ១0 | ៧00ម |
| ៧ | ឆក់ | គ្រឿង | ១២0 | |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកអុំ | ៥0 | ២00-៣00 គ.ក្រ | |
| ទូកម៉ាស៊ីន | ១0 | ១000-១៥00 គ.ក្រ | ១៨-២0 |

**គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ**

នៅក្នុងសហគមន៍នេសាទដូងជ្រុំ អ្នកនេសាទមានចំនួន ៣៦៩ (៧0+៤៨៣ អ្នកក្រៅ) គ្រួសារបានប្រើប្រាស់ឧបករណ៍ច្រើនប្រភេទដើម្បីធ្វើ នេសាទ មានដូចជា មងរាយ លប សំណាញ់ ទ្រូ សន្ទូចរនង សន្ទូចប្របក់ បង្កៃ អួនពាក់ អួនអូស លបលួង ជុច លាន់ ឈ្នាង ជួអន្ទង់ ជួកន្ទេះឡង់ លបកង្កែប ។ ការប្រើប្រាស់ឧបករណ៍ទាំងនេះ បានអនុវត្តស្ទើរតែគ្រប់រដូវទាំងរដូវប្រាំង និងរដូវវស្សា ។ ផលនេសាទដែលទទួលបាន មានចំរុះ ដូចជាត្រី អន្ទង់ កង្កែប កន្ទេះឡង់ ក្តាមខ្យង កំពិស ត្រីល្អិត។ ។ ក្រៅពីទុកហូប និងកែច្នៃ ផលនេសាទមួយភាគធំបានលក់ដូរដើម្បីប្រាក់ចំណូលក្នុងគ្រួសារ ។ *ផលនេសាទទាំងនេះដូចមានសង្ខេបដូចតារាងខាងក្រោម:*

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី (ផ្ទុក រស់ ដៀប ចំរុះ) | ៤២0៥២0 | ៥00.៦00 | ៩២១.0៣១ |
| ក្តាម ខ្យង កំពិស | ៧៦0 | ៧៧៨ | ១៥៣៨ |
| អន្ទង់ | ១៥៨៩0 | ១0000 | ២៥៨៩0 |
| កង្កែប | 0 | 0 | 0 |
| កន្ទេះឡង់ | 0 | 0 | ៣ |
| **សរុប** | **៤៣៧.១៧0** | **៥១១.៣៧៨** | **៩៤៨.៥៤៨ គ.ក** |

**<u>ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី ៣:</u> ផលចាប់តាមប្រភេទឧបករណ៍នេសាទ ។**

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនះវិស័យ

សហគមន៍នេសាទ ដូងជ្រុំ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយសមធមិ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ដែលបានលុបឬកាត់បន្ថយពីនាទីឡូត៍នេសាទ និងដែននេសាទដែល ត្រូវការពារព្រៃលិចទឹក ។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និង ធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម ។
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពី ប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

**ផែនការប្រើប្រាស់ ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:**

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹង អូរ | ៨-១១ | មង | ប្រវែងមិនលើសពី ២៥០ម | ៧៣ | |
| បឹង អូរ | ៣-៦ | អួន | ប្រវែងមិនលើសពី ៤០ ម | ២ | |
| បឹង អូរ | ៨-១០ | ថ្នង | ទំហំមិនលើសពី ២,៥ ម | ២ | |
| បឹង អូរ | ១-៥ | អញ្ចង | ប្រវែងមិនលើសពី ៦ម | ២៥ | |
| បឹង អូរ | ៨-១១ | សន្ទូចរនង | មិនលើសពី ៥០០ផ្លែ | ១២២ | |
| បឹង អូរ | ១-៥ | សំណាញ់ | ប្រវែងមិនលើសពី ៦ម | ៤២ | |
| បឹង អូរ | ១-១២ | លាន់ | មិនលើសពី ៥០ គ្រឿង | ៦៨ | |
| វាលស្រែ | ៩-១ | ទ្រូ | ចំនួនមិនលើសពី ៦ គ្រឿង | ៣៧ | |
| បឹង អូរ | ១-១២ | ជូអន្ទង់ | ចំនួនមិនលើសពី ៤០ គ្រឿង | ៦១ | |
| បឹង អូរ | ៧-១១ | លប | ០,៨០ម x១,២ម ព្រួល២,៥ម ហាមតភ្ជាប់គ្នាមិនលើសពី១០គ្រឿង | ៣៦ | |

*សំគាល់:* <u>*ការប្រើប្រាស់ឧបករណ៍នេសាទនេះនឹងមានការកែប្រែបន្ទាប់ពីមានសេចក្តីប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ។*</u>

### គ.២ ផែនការកែលំអរដែននេសាទ

សហគមន៍នេសាទដូងជ្រុំ សំបូរទៅដោយដែននេសាទ ជាពិសេសបឹងនានាក្នុងព្រៃប្រទល់ ដែលសហគមន៍គ្រប់គ្រង ។ ដែននេសាទមួយចំនួន មានការរីងរាក់ នៅរដូវប្រាំង ដែលទាក់ទងនិងជម្រកមច្ឆជាតិ ដែលមាននៅក្នុង

សហគមន៍ ។ សហគមន៍នេសាទបានធ្វើការព្រមព្រៀងគ្នា ធ្វើការស្តារបឹងមួយកន្លែង ដែលមានទំហំបណ្តោយ ៥០ម ទទឹង ៥០ម និងជំរៅ ៣ម ។

**ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ**

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ស្តារបឹងហា | ៧០ x ៦០០ | ៥០មX៥០មX៣ម | ១-រៀបចំផែនការ | ខែ៤-០៨ | ខែ៥-០៨ | ប្រជុំគ.ស.ន |
| | | | ២-កំណត់ទីតាំងត្រូវស្តារ | ខែ៥-០៨ | ខែ៦-០៨ | ពិនិត្យជាក់ស្តែង |
| | | | ៣-គៀងគរធនធាន | ខែ៥-០៨ | ខែ៧-០៨ | ប្រមូលធនធាន |
| | | | ៤-អនុវត្តការបូមស្តារបឹង | ខែ៤-០៨ | ខែ៧-០៨ | តាមដានអនុវត្ត |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

បឹងហា ជាបឹងមួយសំបូរទៅដោយមច្ឆជាតិ ។ សហគមន៍បានជ្រើសរើស បឹងទាំងនេះ សំរាប់ជាកន្លែងអភិរក្ស ត្រីមេពូជដើម្បីបង្កើនធនធានជលផល ។ ដោយយោងលើផែនការស្តារបឹងខាង លើកន្លែងនេះអាចសមស្រប ជាកន្លែង អភិរក្សត្រីមេពូជ ។

**ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងហា | ៧០មX៦០០ម | ការពារត្រីមេពូជ (ដើម្បីបង្កើនធនធាន ជលផល) | ១-កំណត់ព្រំប្រទល់ | ខែ០២-០៨ | ០៤-០៨ | |
| | | | ២-បោះបង្គោល | ០២-០៨ | ១១-០៨ | |
| | | | ៣-ដាំព្រៃលិចទឹក | ០២-០៨ | ១២-០១០ | |
| | | | ៤-ដាក់ផ្លាកសញ្ញា | ០១-០៨ | ០២-០៨ | |
| | | | ៥-ដាក់លូ ៣០០ | ០៤-០៨ | ០៥-០៨ | |
| | | | ៦-ចុះល្បាតប្រចាំការ | ០១-០៨ | ១២-០១០ | |
| | | | ៧-សង់រោងល្បាត | ០១-០៨ | ០៥-០១០ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ព្រៃលិចទឹក មានសារៈសំខាន់ណាស់សំរាប់ជាជំរកពពួកមច្ឆជាតិ វារីសត្វនិងរុក្ខជាតិគ្រប់ប្រភេទ ជាជម្រក កន្លែងពង កូន កន្លែងលាក់ខ្លួននិងការបង្កកំណើតរបស់ពពួកមច្ឆជាតិ និងសត្វគ្រប់ប្រភេទ ។ ការបាត់បង់ព្រៃលិចទឹក អាចបណ្តាល ឱ្យធនធានជលផលថយចុះ ។ ព្រៃលិចទឹកនៅក្នុងសហគមន៍នេះទទួលរងនូវការបាត់បង់ខ្លះៗដោយសារ ទង្វើមនុស្ស ជាពិសេស ការដុតបំផ្លាញ ការបរបាញ់សត្វ និងការកាប់ទន្រ្ទានរានដីព្រៃ ។ ដើម្បីកែលំអធនធានព្រៃលិច

ទឹកនេះ និង រួមចំណែកបង្កើនធនធានជលផល សហគមន៍នេសាទបានរៀបចំផែនការស្តារដោយដាំព្រៃលិចទឹកឡើងវិញ បង្កើត កន្លែងអភិរក្សព្រៃលិចទឹកនិងការអនុវត្តការដកហូតតាមបច្ចេកទេសដើម្បីរក្សាបានធនធានព្រៃលិចទឹកឱ្យនៅគង់វង្ស។

**ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោម៖**

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃ ខែឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក បឹងជាតិអង្គល់ បឹងដំណាក់ចោង | ៣៩ ហត | រាំង ត្រស់ តួរ បបួយ គុម្ពភ្លៀង... | ១-ប្រមូលគ្រាប់ពូជ | ១០-០៨ | ១២-០១០ | រើសពូជ |
| | | | ២- ធ្វើថ្នាលបណ្តុះកូនឈើ | ១០-០៨ | ០៥-០១០ | រៀបចំថង់ |
| | | | ៣-ថែរក្សាកូនក្នុងថ្នាល | ១០-០៨ | ០៥-០១០ | ថែទាំ |
| | | | ៤-ដាំកូនឈើ | ០៥-០៨ | ០៦-០៨ | ដាំកូន |
| | | | ៥-ថែរក្សា ការពារ | ០៥-០៨ | ១២-០១០ | ថែទាំ |
| ២- បង្កើតកន្លែងអភិរក្ស ចាប់ពីអូរជ្រៅដំណាក់រវាងទៅជើង | ១៦៦.៨៩ ហត | គ្រប់ប្រភេទ | ១-កំណត់ទីតាំង | ០៧-០៨ | ០៧-០៨ | បង្គោល |
| | | | ២-ដាក់ផ្ទាំងប៉ាណូ ៣ | ០៨-០៨ | ១០-០៨ | ៤ផ្ទាំង |
| | | | ៣-ផ្សព្វផ្សាយ | ០៧-០៨ | ១២-០១០ | |
| | | | ៤-ល្បាត | ០៧-០៨ | ១២-០១០ | |
| ៣-ថែរក្សា និង រំលោះព្រៃលិចទឹក | ៣១៧.៤១ ហត | | | ០១-០៨ | ០៦-០៨ | |
| | ១៨៥.០២ ហត | | | ០១-០៩ | ០៦-០៩ | |
| | ២៨៥.៨៩ ហត | | | ០១-០១០ | ០៦-០១០ | |

- ផែនការឆ្នាំទី១ ទីតាំងត្រូវដាំចំនួន ០៥ ហតៈ នៅទីតាំង បឹងជាតិអង្គល់ ។
- ផែនការឆ្នាំទី២ មានចំនួន ០៥ ហតៈ នៅទីតាំង បឹងដំណាក់ចោង
- ផែនការឆ្នាំទី៣ មានចំនួន ០៥ ហតៈ នៅទីតាំង បឹងដំណាក់ចោង ដែលត្រូវកំណត់ជាបន្តបន្ទាប់ នៅពេលដែល ផែនការឆ្នាំទី១ ឆ្នាំទី២បានអនុវត្តរួច ។ ផែនការឆ្នាំទី១ ដាំកូនឈើ ៥០០០ដើម ក្នុង១មួយឆ្នាំ ហើយចំនួននេះមានការ កើនឡើងនៅឆ្នាំទី២ និងទី៣ ជាបន្តបន្ទាប់ ។ សហគមន៍ត្រូវការបច្ចេកទេសលើការបណ្តុះកូនឈើ និងការដាំកូនឈើ និងការដកហូតតាមបច្ចេកទេស ។

### ត.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ដោយសារធនធានជលផល ជាពិសេសត្រី ដែលរកបាននៅក្នុងដែននេសាទសហគមន៍ មានកំរិតទៅនិង តំរូវការរបស់ សហគមន៍ សមាជិកសហគមន៍មានផែនការអភិវឌ្ឍន៍វារីវប្បកម្ម (ចិញ្ចឹមត្រីតាមស្រះជាលក្ខណៈ គ្រួសារ ) ត្រូវបាន រៀបចំឡើងដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ១០ | ត្រីអណ្តែង ទីឡាព្យា គន្ធរ ប្រា ឆ្ពិន | ៣០០-៥០០ក្បាល/ស្រះ | ០៦-០៨ | ១២-៨០ |

| | | | | | |
|---|---|---|---|---|---|
| ស្រះ | ១០ | ត្រីអណ្តែង ទីឡាព្យា គន្ធរ ប្រា ឆ្កិន | ៣០០-៥០០ក្បាល/ស្រះ | ០៦-០៨ | ១២-០៩ |
| ស្រះ | ១០ | ត្រីអណ្តែង ទីឡាព្យា គន្ធរ ប្រា ឆ្កិន | ៣០០-៥០០ក្បាល/ស្រះ | ០៦-០៨ | ១២-០១០ |

ចិញ្ចឹមត្រីក្នុងស្រះ ជាមធ្យមទំហំ បណ្តោយ ១០ម ទទឹង ៥ម ជំរៅស្រះ ៣ម ។ ទំហំអាចធំជាងនេះទៅតាមលទ្ធភាព និងធនធានដែលមានរបស់អ្នកចិញ្ចឹមនីមួយៗ ។ ផែនការចិញ្ចឹមត្រីក្នុងស្រះឆ្នាំទី១ មានចំនួន ២០ស្រះ ឆ្នាំទី២ ២០ ស្រះ និងឆ្នាំទី៣ ២០ ស្រះ ។ ចំនួននេះអាចមានការប្រែប្រួលទៅតាមតំរូវការសហគមន៍ និងទីផ្សារ ។ សហគមន៍ត្រូវការបច្ចេកទេសសមស្របលើការចិញ្ចឹមត្រី ដើម្បីទទួលបានផលច្រើន ។

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

យោងតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ចំណូលសហគមន៍បានមកភាគទានពីសមាជិកសហគមន៍ ភាគទានប្រចាំឆ្នាំ ។ ភាគទានទាំងនេះសមាជិកសហគមន៍ត្រូវធ្វើការបង់ជារៀងរាល់ឆ្នាំ សំរាប់សកម្មភាពការងារសហគមន៍នេសាទ ។ ក្រៅពីនេះសហគមន៍អាចទទួលថវិកាទ្រទ្រង់សហគមន៍សំរាប់ការអភិវឌ្ឍន៍សហគមន៍ ពីគំរោងកម្មវិធីអង្គការនានា និងពីក្រុមប្រឹក្សាឃុំ ទៅតាមសកម្មភាពជាក់លាក់ តាមរយៈការលើកផែនការសកម្មភាព ការស្នើសុំដោយសរសេរ គំរោងស្នើសុំ ។

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ១-ចុះប្រមូល | ០១-០៨ | ១២-០៨ | ៥០០ ៛ | |
| ភាគទានប្រចាំឆ្នាំ | ១-ចុះប្រមូល | ជារៀងរាល់ឆ្នាំ | រហូត | ២.៤០០ ៛ | |
| ជំនួយសម្បុរសជន និងអង្គការនានា | គំរោងស្នើសុំ | ០១-០៨ | រហូត | ៣.០០០ $<br>៥.០០០ $ | |

## គ-៧ ផែនការទ្រទ្រង់ជីវភាពសហគមន៍

នៅក្នុងសហគមន៍នេសាទ ដូងជ្រុំ សមាជិកសហគមន៍នេសាទភាគច្រើនពឹងផ្អែកលើការធ្វើស្រែចំការ និងមានមុខរបរបន្ទាប់បន្សំខ្លះដូចជា ដាំបន្លែ ចិញ្ចឹមសត្វ ស៊ីឈ្នួល លក់ពលកម្ម ។ល។ សហគមន៍លើកឡើងនូវជំរើសមុខរបរបន្ថែមដើម្បីរួមចំណែកបង្កើនជីវភាព និងប្រាក់ចំណូលគ្រួសារ ក្នុងនោះមានដូចជា ដាំបន្លែ បណ្តុះផ្សិត ចិញ្ចឹមមាន់ ទា ជ្រូក ទាកបា ធ្វើជីកំប៉ុស្ត ចិញ្ចឹមជន្លេន ថ្នាលបណ្តុះកូនឈើ ចិញ្ចឹមត្រី ។ល។ ក្នុងផែនការទ្រទ្រង់ជីវភាពឆ្នាំទី១ មានដូច ចែងក្នុងតារាង ហើយតួលេខ ចំនួនគ្រួសារនេះ អាចកើនឡើងជាបន្តបន្ទាប់សំរាប់ឆ្នាំទី២ និងទី៣ ។

**<u>តារាងផែនការទ្រទ្រង់ជីវភាពសហគមន៍៖</u>**

| មុខរបរ | ចំនួនគ្រួសារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ដាំបន្លែ គ្រប់មុខ | ១០០ | ១-រៀបចំរង<br>២-សាបពូជ<br>៣-តាមដាន ថែទាំ | ០២-០៨ | ១២-០៩ | -ត្រូវការពូជបន្លែ<br>-ខ្វះបច្ចេកទេស |

| | | | | | |
|---|---|---|---|---|---|
| | | ៤-ប្រមូលផល | | | |
| បណ្តុះផ្សិត | ១៥ | ១-រៀបចំថ្នាល<br>២-រៀបចំចំបើង<br>៣-ដាក់មេផ្សិត<br>៤-ថែទាំ និងប្រមូលផល | ០១-០៨ | ១២-០១០ | -ត្រូវការមេផ្សិត<br>-ខ្វះបច្ចេកទេស |
| ចិញ្ចឹមមាន់ | ២៥០ | ១-រៀបចំទ្រុង<br>២-ដាក់ពូជ<br>៣-ថែទាំ | ០១-០៨ | ១២-០១០ | -ខ្វះពូជមាន់ញីឈ្មោល<br>-ខ្វះបច្ចេកទេស |
| ចិញ្ចឹមទាកាប | ១០ | ១-រៀបចំទីកន្លែង<br>២-ដាក់ពូជ<br>៣-ថែទាំ<br>៤-ប្រមូលផល | ០១-០៨ | ១២-០១០ | ខ្វះពូជទា |
| ចិញ្ចឹមជ្រូក | ២០០ | ១-រៀបចំទ្រុង<br>២-ដាក់ពូជ<br>៣-ថែទាំ | ០១-០៨ | ១២-០១០ | -ត្រូវការពូជជ្រូក សាច់ ជ្រូកញី<br>-ខ្វះបច្ចេកទេស |
| ចិញ្ចឹមទាកាប៉ា | ៣០០ | ១-រៀបចំទ្រុង<br>២-ដាក់ពូជ<br>៣-ថែទាំ | ០១-០៨ | ១២-០១០ | -ពូជទាកាប៉ា<br>-ខ្វះបច្ចេកទេស |
| ធ្វើជីកំប៉ុស្ត ជីសរីរាង្គ | ១៥០ | ១-ធ្វើទ្រុងកំប៉ុស្ត<br>២-ប្រមូលជីដាក់ទ្រុង<br>៣-ពិនិត្យ ថែទាំ<br>៤-ប្រមូលដាក់ស្រែ | ០១-០៨ | ១២-០១០ | -មានលាមកគោក្របី អាចរកបាន<br>-ខ្វះបច្ចេកទេស |
| ចិញ្ចឹមជន្លេន | ៥ | ១-ធ្វើថ្នាលចិញ្ចឹម<br>២-ដាក់ពូជ<br>៣-ផ្តល់ចំណី<br>៤-ប្រមូលផល | ០៦-០៨ | ១២-០១០ | -ពូជជន្លេន<br>-ខ្វះបច្ចេកទេស |
| ថ្នាលបណ្តុះកូនឈើ | ៥ | ១-រកពូជ គ្រាប់<br>២-រៀបចំថ្នាល<br>៣-រៀបចំថង់ ច្រកដី<br>៤-ដាក់គ្រាប់ពូជ<br>៥-ថែទាំ | ០១-០៨ | ១២-០១០ | -ប្រមូលគ្រាប់ ពូជឈើហូបផ្លែ អាចលក់ដូរនិងដាំ តាមគ្រួសារ<br>-ខ្វះបច្ចេកទេស |
| ចិញ្ចឹមត្រី | ៣០ | ១-រៀបចំស្រះ<br>២-រកពូជ<br>៣-ដាក់ពូជ<br>៤-ថែទាំ | ០៦-០៨ | ១២-០១០ | -ត្រីអណ្តែង ទីឡាព្យា គន្ធរ<br>-ខ្វះបច្ចេកទេស |

## គ-៤ ផែនការបង្កើនសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ការបង្កើនសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ផែនការសំខាន់សំរាប់គណៈកម្មការធ្វើការដឹកនាំ និង គ្រប់គ្រង ក៏ដូចជាពង្រឹងស្ថាប័នរបស់ខ្លួនឱ្យមានភាពរឹងមាន ការដឹកនាំប្រកបដោយប្រសិទ្ធិភាព ។ គណៈកម្មការសហគមន៏ នេសាទ បានលើកឡើងនូវតំរូវការបណ្តុះបណ្តាល វគ្គខ្លីៗទាំងជំនាញគ្រប់គ្រង ការដឹកនាំសហគមន៏នេសាទ ការរៀបចំ ផែនការសកម្មភាពសហគមន៏ ការគ្រប់គ្រងគំរោងតូចៗ ការសរសេរគំរោងស្នើសុំ ការធ្វើកំណត់ហេតុ របាយការណ៍ ជំនាញបច្ចេកទេសលើការទ្រទ្រង់ជីវភាព និងបង្កើនការយល់ដឹងពីច្បាប់និងលិខិតបទដ្ឋានទាក់ទង និងវិស័យជលផល ពិសេសការងារគ្រប់គ្រងសហគមន៏នេសាទ ។ ប្រធានបទមួយចំនួនត្រូវបានធ្វើការកំណត់កំឡុងពេលធ្វើផែនការ និងវិភាគបញ្ហាជាមួយគណៈកម្មការ ។ ប្រធានបទទាំងនេះអាចមានការប្រែប្រួលទៅតាមតំរូវការ បន្ថែមទៀតទៅ តាមការរីកចំរើន និងចំណេះដឹងរបស់គណៈកម្មការសហគមន៏នេសាទ។

**តារាងផែនការបង្កើនសមត្ថភាពគណៈកម្មការសហគមន៏នេសាទ:**

| ប្រធានបទ | អ្នកចូលរួម | លទ្ធផលរំពឹងទុក | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ១-ការសរសេរគំរោង | គ.ស.ន | គ.ស.នចេះសរសេរគំរោងស្នើសុំ | ០១-០៨ | ១២-០១០ | |
| ២-ការសរសេររបាយការណ៏ | គ.ស.ន | ចេះសរសេររបាយការណ៏ | ០១-០៨ | ០២-០៨ | |
| ៣-ការធ្វើកំណត់ហេតុ | គ.ស.ន | មានលទ្ធភាពសរសេរកំណត់ហេតុ | ០១-០៨ | ០២-០៨ | |
| ៤-ផ្សព្វផ្សាយច្បាប់ជលផល លិខិតបទដ្ឋាន អនុក្រិត្យស.ន | គ.ស.ន | មានការយល់ដឹងលើការងារច្បាប់ និងលិខិតបទនានាទាក់ទាងស.ន | ១-០៨ | ២-០៨ | |
| ៥-ការត្រួតពិនិត្យ វាយតំលៃ | គ.ស.ន | មានការយល់ដឹងលើការចូលរួម ត្រួតពិនិត្យ និងវាយតំលៃ | ៣-០៨ | ៤-០៨ | |
| ៦-ការធ្វើផែនការ | | មានផែនការប្រចាំឆ្នាំរាល់ឆ្នាំ | ០១-០៨ | ០៣-០៨ | |
| ៧-ជំនាញបច្ចេកទេស: | គ.ស.ន | មានជំនាញបច្ចេកទេសសមស្រប ដើម្បីបង្កើនជីវភាពគ្រួសារ | ០១-០៨ | ១២-០១០ | |
| ៧-១ ដាំស្រូវតាមប.វ.ស | គ.ស.ន | | ០៥-០៨ | ១២-០១០ | |
| ៧-២ ចិញ្ចឹមសត្វមាន់ទាជ្រូក | គ.ស.ន | | ០១-០៨ | ១២-០១០ | |
| ៧-៣ ចិញ្ចឹមជន្លេន | គ.ស.ន | | ០១-០៨ | ១២-០១០ | |
| ៧-៤ បណ្តុះផ្សិត | គ.ស.ន | | ០១-០៨ | ១២-០១០ | |
| ៧-៥ ជីកំប៉ុស្ត | គ.ស.ន | | ០១-០៨ | ១២-០១០ | |
| ៧-៦ ចិញ្ចឹមត្រី | គ.ស.ន | | ០១-០៨ | ១២-០១០ | |

## គ-៥ ផែនការចធ្សោបាយសំរាប់បំរើការងាររបស់សហគមន៏

ដើម្បីលើកកំពស់ការការពារនិងអភិរក្សធនធានធម្មជាតិក្នុងកន្លែងនេសាទសហគមន៍ឱ្យមានប្រសិទ្ធិភាពខ្ពស់ តាមរយៈការ បំពាក់មធ្យោបាយធ្វើដំណើរសមស្របដល់សហគមន៍នេសាទ ដើម្បីបំរើការងារល្បាតសហគមន៍ ជាងនេះទៀតសហគមន៍នេសាទបានជួបប្រទះនូវបញ្ហាមួយចំនួន ដូចជាការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដោយប្រើឧបករណ៍ឆក់ត្រី ការកាប់បំផ្លាញព្រៃលិចទឹក ការដាក់សំរះ និងប្រើប្រាស់ឧបករណ៍ដែលហាមឃាត់ ជាពិសេសអ្នកមកប្រើប្រាស់ធនធានមកពីខាងក្រៅ។ ការយាមល្បាតមិនបានគ្រប់ជ្រុងជ្រោយដោយ សារគណៈកម្មការសហគមន៍នេសាទមានការខ្វះខាតមធ្យោបាយសម្ភារៈសំរាប់ធ្វើការល្បាតដើម្បីទប់ស្កាត់ និង បង្ក្រាប បទល្មើសនេសាទសហគមន៍ក្នុងដែននេសាទរបស់ខ្លួន ។

**ផែនការមធ្យោបាយសំរាប់បំរើការងាររបស់សហគមន៏ៈ**

| **បរិយាយ** | **សកម្មភាព** | **លទ្ធផលរំពឹងទុក** | **ថ្ងៃខែឆ្នាំ ចាប់ផ្តើម** | **ថ្ងៃខែឆ្នាំ បញ្ចប់** | **ផ្សេងៗ** |
|---|---|---|---|---|---|
| -មធ្យោបាយធ្វើការងារ<br>-ស្នាក់ការ ០១ គ្រឿង<br>-កាណូត ០១ គ្រឿង<br>-ទូក ០៣ គ្រឿង<br>-វិទ្យុទាក់ទង ០៣ គ្រឿង<br>- កង់ ០៥ គ្រឿង | -រៀបចំផែនការ<br>-ស្វែងរកប្រភពជំនួយ<br>-ដេញថ្លៃ | គណៈកម្មការសហគមន៏នេសាទមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញការងារនិងការរក្សាឯកសារផ្សេងៗ | ០១-០៨ | ១២-០៩ | |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

១- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៏ផែនការរួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ។

២- ស្នើសុំជំនួយបច្ចេកទេសពីសមត្ថកិច្ចជលផលដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែង អភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម ។

៣- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ

៤- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់

៥- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងស.ន

៦- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ

៧- គៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ

៨- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍

៩- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ

១០- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ

១១- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដូងថ្មី រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ១. ផ្សព្វផ្សាយលើការប្រើប្រាស់ឧបករណ៍<br>២. ត្រួតពិនិត្យលើការប្រើប្រាស់ឧបករណ៍នេសាទ | • មានត្រីហូបគ្រប់គ្រាន់<br>• ធ្វើឱ្យធនធានមាននិរន្តរភាព<br>• សហគមន៍និងអ្នកនេសាទទាំងអស់គោរពទៅតាមបទបញ្ជាផ្ទៃក្នុង<br>• បទល្មើសនេសាទបានកាត់បន្ថយ | ១៧០០ ដុល្លារ (៦,៨លានរៀល) | ថវិកាសហគមន៍ | ០១-០៨ | ១២-០១០ | |
| ២. ការកែលំអដែននេសាទ | ១-រៀបចំផែនការ<br>២-កំណត់ទីតាំងត្រូវស្ដារ<br>៣-គៀងគរធនធាន<br>៤-អនុវត្តការបូមស្ដារបឹង | • មានប្រភពទឹក និងបង្កើនធនធានជលផល | ១០០០ ដុល្លា (៤លានរៀល) | PIU ជលផល និង អង្គការនានា | ១២-០៨ | ០៥-០១០ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | ១-កំណត់ព្រំប្រទល់<br>២-បោះបង្គោល<br>៣-ដាក់ផ្លាកសញ្ញា<br>៤-ដាក់លូ ១០០<br>៥-ចុះល្បាតប្រចាំការ | • មានជំរកមច្ឆជាតិ និងបង្កើនផលធានជលផល | ១០០០ ដុល្លា (៤លានរៀល) | PIU ជលផល | ០៧-០៨ | ០៥-០៩ | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | ១-ធ្វើថ្នាលបណ្ដុះកូនឈើ<br>២-ដាំព្រៃលិចទឹក<br>៣-ថែរក្សាព្រៃចាស់<br>៤-កំណត់កន្លែងអភិរក្ស | • ថ្នាលចំនួន ២បានបង្កើត<br>• កូនឈើចំនួន ៥០០០ ដើមបានដាំលើផ្ទៃដីចំនួន ២ហត<br>• ផ្ទៃដីព្រៃលិចទឹកចំនួន ១៥ ហត | ១០០០ ដុល្លា (៤លានរៀល) | PIU ជលផល | ០១-០៨ | ១២-០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ៥-ផែនការដកហូត | បានការពារ<br>• កន្លែងអភិរក្ស១កន្លែងបានធ្វើការអភិរក្ស<br>• ផែនការដកហូតតាមបច្ចេកទេស | | | | | |
| ៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ១-ចិញ្ចឹមត្រីតាមស្រះ<br>២-រៀបចំស្រះ និងកែលំអស្រះ<br>៣-ផ្តល់ចំណី<br>៤-ថែរក្សា | • ត្រីចំនួន ២០ស្រះត្រូវបានចិញ្ចឹមក្នុងឆ្នាំនិមួយៗ<br>• កូនត្រីចំនួន ៣០០០-៥០០០ ក្បាលក្នុងមួយស្រះ | ១០០០ ដុល្លា (៤លានរៀល) | PIU ជលផល និង អង្គការនានា | ០១-០៨ | ១២-០១០ | |
| ៦- ផែនការថវិកាទ្រទ្រង់ការអភិវឌ្ឍន៍សហគមន៍ | ១-ប្រមូលប្រាក់ភាគទានស.ន<br>២-ទំនាក់ទំនងជាមួយគំរោង កម្មវិធី អង្គការនានា និងក្រុម ប្រឹក្សាឃុំ និងស្ថាប័នជំនាញ<br>៣-សរសេរគំរោងស្នើសុំជំនួយ<br>៤-តាមដានគ្រប់គ្រងហិរញ្ញវត្ថុ | • ប្រាក់ភាគទានបានធ្វើការប្រមូល និងប្រើប្រាស់សំរាប់គោលបំណងអភិវឌ្ឍន៍ស.ន<br>• សហគមន៍មានថវិកាសំរាប់អភិវឌ្ឍន៍គំរោងសកម្មភាព<br>• ស.ន មានការរីក ចំរើន | ១០០០ ដុល្លា (៤លានរៀល) | ភាគទានសមាជិក ស.ន អង្គការអភិវឌ្ឍន៍នានា ក្រុមប្រឹក្សាឃុំ គំរោងកម្មវិធីនានា | ០១-០៨ | ១២-០១០ | |
| ៧-ផែនការទ្រទ្រង់ជីវភាពសហគមន៍ | ១-ជ្រើសរើសកសិករ<br>២-បណ្តុះបណ្តាលបច្ចេកទេសៈ<br>• ដាំបន្លែ បណ្តុះផ្សិត ចិញ្ចឹមត្រី<br>• ចិញ្ចឹមមាន់, ចិញ្ចឹមទាកាប<br>• ចិញ្ចឹមជ្រូក, ចិញ្ចឹមទាកាប៉<br>• ធ្វើជីកំប៉ុស្ត, ចិញ្ចឹមជន្លេន | • កសិករត្រូវបានជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យ<br>• អ្នកចូលរួមកើនចំណេះជំនាញបច្ចេកទេសលើការអនុវត្តន៍<br>• កសិករមានជីវភាព និងប្រាក់ចំណូលកើនឡើង | ៧០០០ ដុល្លារ (២៨លានរៀល) | ភាគទានសមាជិកស.ន អង្គការអភិវឌ្ឍន៍នានា ក្រុមប្រឹក្សាឃុំ គំរោងកម្មវិធីនានា | ០១-០៨ | ១២-១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | • ថ្នាលបណ្ដុះកូនឈើ<br>៣-រៀបចំផែនការ រកធនធាន<br>៤-អនុវត្តផែនការ<br>៥-តាមដានគាំទ្របច្ចេកទេស | | | | | | |
| ៨-ផែនការបង្កើនសមត្ថភាពគ.ស.ន<br>-បោះបង្គោលព្រំប្រទល | ១. ធ្វើផែនការបណ្ដុះបណ្ដាល<br>២. កំណត់ប្រធានបទ<br>៣. រកអ្នកផ្ដល់សេវាបណ្ដុះបណ្ដាល<br>៤. អនុវត្តផែនការបណ្ដុះបណ្ដាល<br>៥. រៀបចំគំរោង<br>៦. ដាក់ដេញថ្លៃ<br>៧. ដំណើរការបោះបង្គោល<br>៨. តាមដានលើការបំពេញការងារ | • គ.ស.ន មានការចំណេះដឹងលើការគ្រប់គ្រង ដឹកនាំ និងជំនាញបច្ចេកទេសសមស្រប<br>• គ.ស.នមានសមត្ថភាពគ្រប់គ្រងសហគមន៍ប្រកបដោយប្រសិទ្ធភាព<br>• សហគមន៍នេសាទមានបង្គោលព្រំប្រទល់ហើយបានបោះរួចជាស្រេច | ៤០០០ ដុល្លារ<br>(១៦លានរៀល) | PIU ជលផល និង អង្គការ និង កម្មវិធីនានា | ០១-០៨ | ១២-០១០ | ត្រូវការគ្រូបណ្ដុះបណ្ដាលលើប្រធានបទជាក់លាក់ និងថវិកា |
| ៩-ផែនការមធ្យោបាយសំរាប់បំរើការងាររបស់សហគមន | ៩. រៀបចំផែនការ<br>១០. រកប្រភពជំនួយ<br>១១. ដាក់ដេញថ្លៃ<br>១២. ស្លាក់ការ ០១ គ្រឿង<br>១៣. កាណូត ០១ គ្រឿង<br>១៤. ទូក ០៣ គ្រឿង<br>១៥. វិទ្យុទាក់ទង ០៣ គ្រឿង<br>១៦. កង់ ០៥ គ្រឿង | គណៈកម្មការសហគមន៍នេសាទមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញការងារនិងការរក្សាឯកសារផ្សេងៗ | ៩.៥០០ ដុល្លារ<br>(៣៨លានរៀល) | ភាគទានសមាជិក ស.ន<br>PIU ជលផល និង អង្គការ ក្រុមប្រឹក្សាឃុំ និង កម្មវិធីនានា | ០១-០៨ | ១២-០១០ | |

# តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០០៨ | | | | | | | | | | | | ២០០៩ | | | ២០១០ | | |
| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | ... | ធ្នូ |
| **១. ការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | |
| ១.១ ផ្សព្វផ្សាយលើការប្រើប្រាស់ឧបករណ៍ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ១.២ ត្រួតពិនិត្យលើការប្រើប្រាស់ ឧបករណ៍នេសាទ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| **២. ការកែលំអដែននេសាទ** | | | | | | | | | | | | | | | | | | |
| ២.១ រៀបចំផែនការ | | | | | | | √ | √ | √ | √ | √ | √ | | | | | | |
| ២.២ កំណត់ទីតាំងត្រូវស្តារ | | | | √ | √ | √ | | | | | | | | | | | | |
| ២.៣ គៀងគរធនធាន | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ២.៤ អនុវត្តការបូមស្តារបឹង | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | | | √ | √ | |
| **៣. ការកំណត់ និងរៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | |
| ៣.១ កំណត់ព្រំប្រទល់ | √ | √ | √ | √ | √ | | | | | | | | | | | | | |
| ៣.២ បោះបង្គោល | | √ | √ | √ | √ | | | | | | | | | | | | | |
| ៣.៣ ដាក់ផ្លាកសញ្ញា | √ | √ | √ | √ | √ | | | | | | | | | | | | | |
| ៣.៤ ដាក់លូ ៣០០ | | | √ | √ | √ | √ | | | | | | | | √ | | √ | | √ |
| ៣.៥ ចុះល្បាតប្រចាំការ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **៤. ផែនការគ្រប់គ្រងព្រៃលិចទឹក** | | | | | | | | | | | | | | | | | | |
| ៤.១ ធ្វើថ្នាលបណ្តុះកូនឈើចំនួន២កន្លែង | | √ | √ | √ | √ | √ | √ | | | | | | | | | | | |
| ៤.២ ដាំព្រៃលិចទឹក | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៤.៣ ថែរក្សាព្រៃចាស់ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៤.៤ កំណត់កន្លែងអភិរក្ស | | | | | | | | | | | √ | √ | | | | | | |
| ៤.៥ ផែនការដកហូតតាមបច្ចេកទេស | | | √ | √ | √ | | | | | | | | √ | √ | √ | √ | √ | √ |
| **៥. ផែនការអភិរក្សវារីវប្បកម្ម** | | | | | | | | | | | | | | | | | | |
| ៥.១ ចិញ្ចឹមត្រីតាមស្រះ | | | | | √ | √ | √ | √ | √ | | | | | | | | | |
| ៥.២ រៀបចំស្រះ និងកែលំអស្រះ | | | | | √ | √ | √ | √ | √ | | | | | | | | | |
| ៥.៣ ផ្តល់ចំណី | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៥.៤ ថែរក្សា | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| **៦.ផែនការថវិកាទ្រទ្រង់ការអភិវឌ្ឍន៍សហគមន៍** | | | | | | | | | | | | | | | | | | |
| ៦.១ ប្រមូលប្រាក់ភាគទានស.ន | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៦.២ ទំនាក់ទំនងជាមួយគំរោងកម្មវិធី អង្គការ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាឃុំ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៦.៣ សរសេរគំរោងស្នើសុំជំនួយថវិកា | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៦.៤ តាមដានគ្រប់គ្រងហិរញ្ញវត្ថុ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| **៧. ផែនការទ្រទ្រង់ជីវភាពសហគមន៍** | | | | | | | | | | | | | | | | | | |
| ៧.១ ជ្រើសរើសកសិករ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧.២ បណ្តុះបណ្តាលបច្ចេកទេស (តាមប្រធានបទ) | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៧.៣ រៀបចំផែនការ គ្រឿងគរធនធាន | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៧.៤ អនុវត្តផែនការ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៧.៥ តាមដានគាំទ្របច្ចេកទេស | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| **៨. ផែនការទ្រទ្រង់ជីវភាពសហគមន៍** | | | | | | | | | | | | | | | | | | |
| ៨.១ ធ្វើផែនការបណ្តុះបណ្តាល កំណត់ប្រធានបទ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៨.២ រកអ្នកផ្តល់សេវាបណ្តុះបណ្តាល | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៨.៣ អនុវត្តផែនការបណ្តុះបណ្តាល | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៨.៤ តាមដានលើការបំពេញការងារ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៨.៥ រៀបចំគំរោងផែនការបោះបង្គោល | √ | √ | √ | √ | | | | | | | | | | | | | | |
| ៨.៦ ដាក់ដេញថ្លៃ | | √ | √ | √ | √ | √ | | | | | | | | | | | | |
| ៨.៧ ដំណើរការបោះបង្គោល | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | | | |
| **៩.ផែនការមធ្យោបាយសំរាប់បំរើការងាររបស់សហគមន៍** | | | | | | | | | | | | | | | | | | |
| ៩.១ រៀបចំផែនការ | √ | √ | √ | | | | | | | | | | | | | | | |
| ៩.២ រកប្រភពជំនួយ | | √ | √ | √ | √ | | | | | | | | | | | | | |
| ៩.៣ ដាក់ដេញថ្លៃ | | | | | √ | √ | √ | | | | | | | | | | | |
| ៩.៤ ស្នាក់ការ ០១ គ្រឿង | | | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៩.៥ កាណូត ០១ គ្រឿង | | | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៩.៦ ទូក ០៣ គ្រឿង | | | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៩.៧ វិទ្យុទាក់ទង ០៣ គ្រឿង | | | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |
| ៩.៨ កង់ ០៥ គ្រឿង | | | | | | | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ |

បានឃើញ និងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់

..........ថ្ងៃទី ..... ខែ ..... ឆ្នាំ ២០០៨

**នាយសង្កាត់រដ្ឋបាលជលផលដងស្ទឹង**

**បានឃើញ**

..........ថ្ងៃទី ២២ ខែ ..០៥... ឆ្នាំ ២០០៨

**មេឃុំ/ចៅសង្កាត់ បឹងបត់កណ្ដាល**

ហ៊ុន_គឹមហ៊ាង

..........ថ្ងៃទី ២២ ខែ ..០៥. ឆ្នាំ ២០០៨

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ :..........

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ..... ខែ ..... ឆ្នាំ ២០០៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

ណៅ_ធួក

លេខ :..........

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួល

បន្ទុកជាប្រធានរដ្ឋបាលជលផល

"ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ"

..........ថ្ងៃទី ..... ខែ ..... ឆ្នាំ ២០០៨

**នាយអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប**

ហួន_..........

លេខ :..........

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល

ខាងត្បូងបឹងទន្លេសាប

ពោធិ៍សាត់, ថ្ងៃទី ..... ខែ ..... ឆ្នាំ ២០០៨

**នាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់**

សេខ_ស៊ុនហ៊ួត

## ឧបសម្ព័ន្ធទី១៖ ដែននេសាទដែលមាននៅក្នុងសហគមន៍នេសាទ

| ល.រ | ឈ្មោះបឹង អូរ | ទំហំ | | | រយៈពេលនេសាទ |
|---|---|---|---|---|---|
| | | បណ្តោយ(ម) | ទទឹង(ម) | ផ្ទៃ (ម² ហត) | |
| ១ | បឹងស្រះប្រជា | ២៥០ | ៧០ | ២,០៧ | ខែ១ ដល់ ខែ៥ |
| ២ | បឹងអាចម៍ដីរ | ១០០ | ៥០ | ០,២៤ | ខែ១០ ដល់ ខែ១១ |
| ៣ | បឹងក្បាលងារ | ១៣០ | ៧០ | ៣,៩៣ | ខែ១២ ដល់ ខែ៥ |
| ៤ | បឹងហា | ៤៣០ | ២៥០ | ២៥,៦៨ | ខែ១២ ដល់ ខែ៥ |
| ៥ | បឹងប្រក្រែវ | ១៥០ | ៤១ | ៣,០៣ | ខែ១២ ដល់ ខែ៥ |
| ៦ | បឹងខ្យង | ១៧០ | ១០០ | ១០,២០ | ខែ១២ ដល់ ខែ៥ |
| ៧ | បឹងតាធីប | ១០០ | ៣០ | ០,២០ | ខែ១២ ដល់ ខែ៥ |
| ៨ | បឹងតាព្រុំ | ៣៥ | ២៥ | ០,២៤ | ខែ១២ ដល់ ខែ៥ |
| ៩ | បឹងអូឫស្សីកូនខ្លា | ៧០០ | ៥០ | ៣៥០០០ | ខែ១២ ដល់ ខែ៣ |
| ១០ | បឹងស្រះចារ្យធំ | ១៧ | ១០ | ០,០៥ | ខែ១២ ដល់ ខែ២ |
| ១១ | បឹងតាស្ទាន | ៤០ | ៣០ | ០,៥០ | ខែ១២ ដល់ ខែ២ |
| ១២ | បឹងត្រឡោក | ១១០ | ៥០ | ០,៥៩ | ខែ១ ដល់ ខែ៥ |
| ១៣ | បឹងថ្លុកតាមែល | ២៥ | ១៥ | ០,៣៤ | ខែ១ ដល់ ខែ៣ |
| ១៤ | បឹងសៀមធំ | ២០០ | ១៥០ | ១,១០ | ខែ២ ដល់ ខែ៤ |
| ១៥ | បឹងកំពង់រលីង | ២០០ | ២០០ | ៨,៧៤ | ខែ២ ដល់ ខែ៥ |
| ១៦ | បឹងជាតិអង្គុលតូច | ៧០០ | ៥០០ | ១០,៣៧ | ខែ២ ដល់ ខែ៥ |
| ១៧ | បឹងជាតិអង្គុលធំ | ៩៥០០ | ៧៥០០ | ១៣,៨១ | ខែ២ ដល់ ខែ៥ |
| ១៨ | បឹងបាតផ្តិល | ៧៣ | ៧០ | ២,២៥ | ខែ២ ដល់ ខែ៤ |
| ១៩ | បឹងប្រហុក | ២៧០ | ១៥០ | ៤,៤៦ | ខែ២ ដល់ ខែ៤ |
| ២០ | បឹងត្រោះក្នុង | ១១៥ | ១០១ | ២,១១ | ខែ២ ដល់ ខែ៤ |
| ២១ | បឹងអកធំ | ១១៨ | ៧៥ | ១,១៧ | ខែ២ ដល់ ខែ៣ |
| ២២ | បឹងខ្សាច់ | ១០៧ | ៦០ | ០,៥០ | ខែ២ ដល់ ខែ៤ |
| ២៣ | បឹងប្របុស | ១២០ | ៨០ | ៩៦០០ | ខែ២ ដល់ ខែ៤ |
| ២៤ | បឹងស្រណាន់ | ២១០ | ១២៥ | ០,៤៧ | ខែ២ដល់ ខែ៤ |
| ២៥ | បឹងតំណាក់កាចោង | ៩០០ | ៤៥ | ៤០៥០០ | ខែ២ ដល់ ខែ៤ |
| ២៦ | បឹងអូត្រាំសេះ | ១០០០ | ១០៧ | ១០៧០០០ | ខែ១២ ដល់ ខែ១២ |
| ២៧ | បឹងវែង | | | ១,២០ | ខែ២ ដល់ ខែ៤ |
| ២៨ | បឹងស្នូក | | | ០,៧០ | ខែ២ ដល់ ខែ៣ |

| | | | | | |
|---|---|---|---|---|---|
| ២៩ | បឹងកំពោងតូច | | | ០,៦៨ | ខែ២ ដល់ ខែ៣ |
| ៣០ | បឹងតាសុន | | | ០,២០ | ខែ២ ដល់ ខែ៣ |
| ៣១ | បឹងតាត្រូ | | | ០,២៦ | ខែ២ ដល់ ខែ៣ |
| ៣២ | ថ្លុកខាងត្បូងកំពង់រលីង | | | ០,២២ | ខែ២ ដល់ ខែ៣ |
| ៣៣ | បឹងសៀមធំ | | | ១,១០ | ខែ២ ដល់ ខែ៣ |
| ៣៤ | បឹងសៀមតូច | | | ០,៤៣ | ខែ២ ដល់ ខែ៣ |
| ៣៥ | បឹងហឿម | | | ០,២២ | ខែ២ ដល់ ខែ៣ |
| ៣៦ | បឹង១ | | | ១,២៧ | ខែ២ ដល់ ខែ៣ |
| ៣៧ | បឹង២ | | | ០,១៥ | ខែ២ ដល់ ខែ៣ |
| ៣៨ | បឹង៣ | | | ០,៦៧ | ខែ២ ដល់ ខែ៣ |
| ៣៩ | បឹង៤ | | | ០,៥៧ | ខែ២ ដល់ ខែ៣ |
| ៤០ | បឹង៥ | | | ០,៣១ | ខែ២ ដល់ ខែ៣ |
| ៤១ | បឹង៦ | | | ០,៦៦ | ខែ២ ដល់ ខែ៣ |
| ៤២ | បឹង៧ | | | ១,២០ | ខែ២ ដល់ ខែ៣ |
| ៤៣ | បឹង៨ | | | ០,០៩ | ខែ២ ដល់ ខែ៣ |
| ៤៤ | បឹង៩ | | | ០,១២ | ខែ២ ដល់ ខែ៣ |
| ៤៥ | បឹង១០ | | | ០,០៦ | ខែ២ ដល់ ខែ៣ |
| ៤៦ | បឹង១១ | | | ០,៣២ | ខែ២ ដល់ ខែ៣ |
| ៤៧ | បឹង១២ | | | ០,២៤ | ខែ២ ដល់ ខែ៣ |
| ៤៨ | បឹង១៣ | | | ០,២៤ | ខែ២ ដល់ ខែ៣ |
| ៤៩ | បឹង១៤ | | | ០,១៣ | ខែ២ ដល់ ខែ៣ |
| ៥០ | បឹង១៥ | | | ០,២៧ | ខែ២ ដល់ ខែ៣ |
| ៥១ | បឹង១៦ | | | ០,៣២ | ខែ២ ដល់ ខែ៣ |
| ៥២ | បឹង១៧ | | | ០,២៩ | ខែ២ ដល់ ខែ៣ |
| ៥៣ | បឹង១៨ | | | ០,៣៨ | ខែ២ ដល់ ខែ៣ |
| ៥៤ | បឹង១៩ | | | ០,១៩ | ខែ២ ដល់ ខែ៣ |
| ៥៥ | បឹង២០ | | | ០,១៤ | ខែ២ ដល់ ខែ៣ |
| ៥៦ | បឹង២១ | | | ០,១៣ | ខែ២ ដល់ ខែ៣ |
| ៥៧ | បឹង២២ | | | ០,១៥ | ខែ២ ដល់ ខែ៣ |
| ៥៨ | បឹង២៣ | | | ០,២៧ | ខែ២ ដល់ ខែ៣ |
| ៥៩ | បឹង២៤ | | | ១,១៧ | ខែ២ ដល់ ខែ៣ |
| ៦០ | បឹង២៥ | | | ១,៨៧ | ខែ២ ដល់ ខែ៣ |

## ឧបសម្ព័ន្ធទី២: ធនធានជលផលដែលមានក្នុងដែននេសាទ

| ល.រ | ពពួកត្រី | ល.រ | ពពួកត្រី | ទារីសត្វ | ល.រ | ទារីរុក្ខជាតិ ព្រៃលិចទឹក | ល.រ | ទារីរុក្ខជាតិ ព្រៃលិចទឹក |
|---|---|---|---|---|---|---|---|---|
| ១ | ផ្ទក់/រ៉ស់ | ៣៧ | ក្បាន | អណ្តើក | ១ | តាសេក | ៣៧ | ចង្កូមក្រពើ |
| ២ | ដៀប/ឆ្តោ | ៣៨ | កំភ្លៀវ | ពស់ | ២ | រាំង | ៣៨ | ស្លូត |
| ៣ | អណ្តែង | ៣៩ | ច្រវាមូល | ក្តាម | ៣ | ត្នួរ | ៣៩ | បន្ទាយូន |
| ៤ | ក្រាញ់ | ៤០ | ក្អិត | ខ្ចៅ | ៤ | ផ្តូល | ៤០ | អំពាក់ |
| ៥ | តាអោន | ៤១ | ច្រវាស្លឹកឫស្សី | ខ្យង | ៥ | ដើមក្រ | ៤១ | ផ្តៅទឹក |
| ៦ | កេស | ៤២ | ប្រមា | លៀស | ៦ | ក្របៅ | ៤២ | ទានព្រៃ |
| ៧ | ស្លាត | ៤៣ | អណ្តាតឆ្កែ | គ្រុំ | ៧ | ក្រសែង | ៤៣ | ស្បូវ |
| ៨ | កញ្ចុះ | ៤៤ | កាព្រាម | អន្ទង់ | ៨ | ផ្តម | ៤៤ | ត្រែង |
| ៩ | ក្រុស | ៤៥ | ក្អក | កន្ធិះឡង់ | ៩ | សណ្តាន់ | ៤៥ | អញ្ចាញ |
| ១០ | រៀល | ៤៦ | ទុំអំពិល | កន្ទាទូក | ១០ | ល្ងៀង | ៤៦ | ឈ្នូក |
| ១១ | លិញ | ៤៧ | កំបុតច្រមុះ | កង្កែប | ១១ | ភ្នំភ្លើង | ៤៧ | ព្រលិត |
| ១២ | ឆ្ពិន | ៤៨ | ពោ | គីងគក់ | ១២ | ប្របួយ | ៤៨ | កន្ទ្រាំងហៃ |
| ១៣ | កាហែ | ៤៩ | ឆ្ពួញ | អន្សង | ១៣ | ត្រស់ | ៤៩ | រំចង់ |
| ១៤ | ប្រា | ៥០ | ក្រឹម | ស្វា | ១៤ | ថ្នើមអណ្តើក | ៥០ | ស្តន់ |
| ១៥ | ឆ្លាំង | ៥១ | គល់រាំង | កន្ធាយ | ១៥ | ដៃខ្លា | ៥១ | ត្រីប |
| ១៦ | ដំរី | ៥២ | ត្រសក់ | ឈ្លើង | ១៦ | ខ្ទុំ | ៥២ | វល្លិត្រី |
| ១៧ | សរ | ៥៣ | កន្ទ្រប់, កន្ទ្រប់ខ្លា | កំពិស | ១៧ | ដើមបាច | ៥៣ | វល្លិប្រេង |
| ១៨ | ច្រកែង | ៥៤ | កញ្ចាក់ស្លា | ភេ | ១៨ | ទ្រនំអាអូត | ៥៤ | ក្តាគន់ |
| ១៩ | ឆ្តោក, ឆ្តោកទីទុយ | ៥៥ | ខ្នងវែង | ខ្លាត្រី | ១៩ | ញ្ញរ | ៥៥ | តាជិត |
| ២០ | ក្អែក | ៥៦ | ស្រកាក្តាម | | ២០ | ធ្មុងកញ្ចុះ | ៥៦ | តាអើក |
| ២១ | គ្រុំ | ៥៧ | | | ២១ | ឈើទៃ | ៥៧ | វល្លិជុយ |
| ២២ | កាឡង់/ព្រួល | | | | ២២ | កន្ទ្រាប់ចង្កេ | ៥៨ | ដូងព្រះ |
| ២៣ | ច្រឡឹង/ព្រលូង | | | | ២៣ | ឈើព្រីង | ៥៩ | វល្លិយាវ |
| ២៤ | កំពត | | | | ២៤ | ប្រាច់ | ៦០ | វល្លិថ្នើមអណ្តើម |
| ២៥ | ខ្ទឹង | | | | ២៥ | ចន្ទល់ភ្នំ | ៦១ | ស្លៃទឹក |
| ២៦ | កញ្ជ្រូក | | | | ២៦ | ត្រកួន | ៦២ | កញ្ឆែត |
| ២៧ | ផ្ទោង | | | | ២៧ | កំពឹងពួយ | ៦៣ | សាវម៉ាវទឹក |
| ២៨ | ខ្នាន់ | | | | ២៨ | សារាយ | ៦៤ | ម៉េងប៉ោះព្រៃ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២៩ | តាណោល | | | | ២៩ | ចក | ៦៥ | កក្អម |
| ៣០ | កញ្ជូនជ័យ | | | | ៣០ | កំប៉ោង/កំប្លោក | ៦៦ | កក់មូល, ជ្រុង |
| ៣១ | អង្កត់ប្រាក់ | | | | ៣១ | តាឡក | ៦៧ | ស្រងៃ |
| ៣២ | បណ្តូលអំពៅ | | | | ៣២ | សង្សរ | ៦៨ | ជផ្លូង |
| ៣៣ | ក្រពាត់/សណ្តាយ | | | | ៣៣ | ពងមាន់ | ៦៩ | |
| ៣៤ | កន្ទ្រាញ់ច្រាស | | | | ៣៤ | កញ្ច្រោស់ | ៧០ | |
| ៣៥ | កំភ្លាញ | | | | ៣៥ | ត្រដក់ | ៧១ | |
| ៣៦ | កន្ទរ | | | | ៣៦ | វល្លិក្រុស | ៧២ | |

## ឧបសម្ព័ន្ធទី៣: ផលចាប់តាមប្រភេទឧបករណ៍នេសាទ

| **លរ** | **ប្រភេទឧបករណ៍នេសាទ** | **ផលចាប់គិតជាគ.ក** | **ប្រភេទផលនេសាទ** |
|---|---|---|---|
| ១ | មងរាយ | ១៣.៥០០ | ត្រីចំរុះ +ពស់ |
| ២ | សំណាញ់ | ៤.២០០ | ត្រីចំរុះ |
| ៣ | ទ្រូ | ១.១១០ | កំពិស ត្រីល្អិតៗ |
| ៤ | លាន់ | ២០.៤០០ | អន្ទង់ |
| ៥ | ឈ្នាង | ៤២៨,៥០ | កំពិស ត្រីល្អិតៗ |
| ៦ | ជូអន្ទង់ | ៥.៤៩០ | អន្ទង់ |
| ៧ | សន្ទូចរនង | ៣០.៤២០ | ត្រីចំរុះ |
| ៨ | ដាយ (ចូ្ប) | ៦៣០.០០០ | ត្រីចំរុះ |
| ៩ | អួនហ៊ុំ | ៤០០ | ត្រីចំរុះ |
| ១០ | អួនអួស | ៣៩.៦០០ | ត្រីចំរុះ |
| ១១ | ឆក់ | ២០៣.០០០ | ត្រីឆ្តោ ដៀប ផ្ទុក រ៉ស់ |
| | **សរុប** | **៩៤៨.៥៤៨,៥០** | |